# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៤-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០២ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្ដម **ឌុច និលគីរី** ពីទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ៩២២៤

២៤-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៣ ស្ដីពី ការកាត់ផ្ទៃដីទំហំ ១០០ ហិកតា ពីដែនជម្រកសត្វព្រៃភ្នំសំកុស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១០ ៩២២៥

២៤-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៤ ស្ដីពី ការកាត់ផ្ទៃដីទំហំ ២.៤១៣ ហិកតា ចេញពីដែនជម្រកសត្វព្រៃរនាមដូនសំ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៣ ៩២២៦

២៤-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៥ ស្ដីពី ការតែងតាំងឯកឧត្ដមសាស្ត្រាចារ្យមហាបរិញ្ញា **កើត មៀច** ជាអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ៩២២៧

២៧-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៦ ស្ដីពី ការតែងតាំងឯកឧត្ដម **គីម សន្តិភាព** ជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជំនួសឯកឧត្ដម **ប៊ុន ហុន** ដែលត្រូវបានទទួលភារកិច្ចថ្មី ៩២២៨

៣០-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៨ ស្ដីពី ការកាត់ផ្ទៃដីទំហំ ៤៤៨ ហិកតា ពីដែនជម្រកសត្វព្រៃបឹងពែរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ៩២២៩

៣០-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៩ ស្ដីពី ការកាត់ផ្ទៃដីទំហំ ១៦.៥៧៧ ហិកតា ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ៣ លេខរៀងទី ១៩ ៩២៣០

០១-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១១ ស្ដីពី ការកាត់ដីទំហំ ១០.៨១៩.៤៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលមានចែងក្នុងមាត្រា ២ ចំណុច ២ លេខរៀង ៨ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ៩២៣១

០៣-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៣ ស្ដីពី ការតែងតាំងឯកឧត្ដម **លី យូគៀត** ជាទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ ៩២៣២

០៣-១២-២០១២-ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ ចំនួន ៥៥ រូប ៩២៣៣

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៦-១១-២០១២-អនុក្រឹត្យលេខ ២១៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំសរុប ៧.៤៩៤ ហិកតា ដែលក្នុងនោះកាត់ចេញពីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ៥.០៨១ ហិកតា និង ពីដែនជម្រកសត្វព្រៃរនាមដូនសំ ទំហំ ២.៤១៣ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៧.៤៣៤ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង និង ដីភ្នំទំហំ ៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកគាស់ក្រឡ និង ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ៩២៣៥

២៦-១១-២០១២ -អនុក្រឹត្យលេខ ២១៤ អនក្រ.បក ស្តីពី ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និង ការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ៩២៤០

២៨-១១-២០១២-អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៥៧១ ហិកតា ដែលក្នុងនោះកាត់ចេញពីតម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ៤៣០ ហិកតា និង ពីក្រុមហ៊ុនភឿកហ្វា ទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង និង ស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ ក្បាលដី និង ដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ ក្បាលដី នៅស្រុកសន្ទុក ខេត្តកំពង់ធំ ៩២៤២

៣០-១១-២០១៤-អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.២៥៨ ហិកតា ដែលក្នុងនោះ (១) កាត់ចេញពីក្រុមហ៊ុនហ្គោលហ្វៃសិន (២) ពីក្រុមហ៊ុនមេគង្គ និង (៣) ពីដែនជម្រកសត្វព្រៃបឹងពែរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤១៧ គ្រួសារ និង ស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤០៨ គ្រួសារ លើ ៦១៦ ក្បាលដី ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅស្រុកប្រាសាទសំបូរ និង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ៩២៤៦

២៣-១០-២០១២-អនុក្រឹត្យលេខ **១៩៧៧** ដល់អនុក្រឹត្យលេខ **២០២៧** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩២៥០

## ២-សេចក្ដីសម្រេច

២៦-១១-២០១២-សេចក្ដីសម្រេចលេខ ៤៧ សសរ ស្ដីពី ការបង្កើតគណៈកម្មការរៀបចំសម័យប្រជុំពេញអង្គលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ៩៣០១

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៧-៨-២០១២ -ប្រកាសលេខ ៤១៥ ប្រក.កសក ស្ដីពី នីតិវិធី និង ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជី ជី កសិកម្ម ៩៣០៥

### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៦-១១-២០១២ -ប្រកាសលេខ ១១០៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីអ៊ិនស៊ី (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩៣៤០

០៦-១១-២០១២ -ប្រកាសលេខ ១១០៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ៃស៊ីង ប្លាស្ទិកប្រដាក់ (ខេមបូឌា) បង្កើតរោងចក្រ ផលិតតម្អក់ព្យួរសម្លៀកបំពាក់ពីប្លាស្ទិក ៩៣៤៤

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខដំណែងឯកឧត្តម **ឈូច និលគីរី** ពីទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៦.១២.១១.២០១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខៈ ៧៥៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ១០០ ហិកតា ពីដែនជម្រកសត្វព្រៃភ្នំសំកុសនៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១០ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩៦១ ច.ល

៣៩៥.១២១១.១០១៣

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ២ ៩១៣ ហិកតា ចេញពីដែនជំរកសត្វព្រៃនាមជូនសំនៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស. ១៧១១.១០០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខ: ៥៦២០.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៥

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្ដមសាស្ដ្រាចារ្យមហាបរិញ្ញា **ភើត មៀច** ជាអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ពរស.១២១១.១០១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខ:៩៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **គឹម សន្តិភាព** ជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម **ម៉ុន ហុន** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ៩៦៩ ប.ល

**ចម្លងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២
**រដ្ឋលេខាធិការទទួលបន្ទុកអគ្គលេខាធិការរាជរដ្ឋាភិបាល**

..ស័ក សុខា

៣រស.១២១១.១០១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : កាត់ផ្ទៃដីទំហំ ៨៤៨ ហិកតា ពីដែនជម្រកសត្វព្រៃបឹងពែរនៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

ពរស. ១២១១. ១០១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២*

លេខៈ ៩៧២ ច.ល
បានថតចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ១៦ ៥៧៧ ហិកតា ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ៣ លេខរៀងទី ១៩ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១២១១.១០០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២*

លេខ:៩៧៣ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ដីទំហំ 10,819.48 ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលមានចែងក្នុងមាត្រា ២ ចំណុច ២ លេខរៀង ៨ នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១២១២.១០៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២

លេខ: ៩៧១ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **លី យូសៀង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បរល. ១២១២.១០២៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ ៩៧៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

មន្ត្រីរាជការ ចំនួន ៥៥រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

**នូវ**

ក- **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ព្រះបវរមុនីញាណ **ស្រួយ គឹមហ៊ាង**
២- ព្រះវិន័យមុនី **ទេព ផាន**
៣- ព្រះភទ្ទសារោ **ម៉ែន គាយ**
៤- លោក **ហ៊ឹម សុផល**
៥- លោកស្រី **ហ៊ីង រតនា**
៦- លោក **ជា គុណរ៉ា**
៧- លោក **ត្លូង ម៉ាល័យ**
៨- លោក **អ៊ុំ ប៊ុនថន**
៩- លោក **សេង សុចិន្តា**
១០- លោកស្រី **ហែម សុភាព**

ខ- **គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **អ៊ិច សំអុល**
២- ឧត្តមសេនីយ៍ទោ **គន្ធ តារាវណ្ណ** អត្ត.០១៣១៥
៣- លោក **ខែម ប៊ុនថៃ**

គ- **គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **សៅ ប៊ុនធឹម**
២- លោក **ឌុច រ៉ាឌុធ**
៣- លោក **លី ប៊ុនហេង**
៤- លោក **គួច ហៃ**
៥- លោក **គួច ជិញថៅ**
៦- លោកស្រី **តែប ម៉ាលី**

ឃ- **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម **អេង សួស្តី**
២- លោក **ម៉ៅត សំណាង**
៣- វេជ្ជបណ្ឌិត **លឹម គ្រួយ**
៤- វិស្វករ **លឹម តាំង**
៥- ល.ស វរសេនីយ៍ឯក **អ៊ិន ច័ន្ទធី** អត្ត.៥៥៩៩៧
៦- វរសេនីយ៍ទោ **គៅ សារ៉ាន់** អត្ត.១៤៩៦៦៨
៧- លោក **យឹម ឋិន**
៨- លោកស្រី **លឹម ស៊ីម**
៩- លោក **ហេង ណុល**
១០- លោកស្រី **ជា ចណ្ណៈ**
១១- លោក **ចាន់ សារិន**
១២- វរសេនីយ៍ត្រី **សៅ សារ៉ុន** អត្ត.០២០៦៩៤
១៣- វរសេនីយ៍ត្រី **អ៊ឹម សុវត្ថិ** អត្ត.១៩៧០៦៨
១៤- លោក **ជួរ សែ**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ង- គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

១- ឧត្តមសេនីយ៍ត្រី អ៊ិន សុទ្ធិរត្ន័ អត្ត.០២១០៦៧ ២- ឧត្តមសេនីយ៍ត្រី សរ ថេង អត្ត.០១០៩៦

៣- វរសេនីយ៍ត្រី សោម សុភ័ណ្ណារ៉ា អត្ត.០១២៩២៥

ច- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១- លោក តិន ស៊ុយ

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក អេង ឌីតូ
២- លោក សួង ហាន
៣- លោក ថុល ស៊ីថេត
៤- លោក ជួប រតនៈ
៥- លោក តាំង ណាឌី
៦- លោក ចាន់ ចាសនា
៧- លោក ឈិត ហាច
៨- លោក រស់ សុគន្ធា
៩- លោក សុត ចន្ទ្ននៈ
១០- លោក ប្លែត ម៉ារី
១១- លោក ម៉ែន សំអួន
១២- អនុសេនីយ៍ឯក អេង តិរម្យ អត្ត.០៩៩៥៩៥

ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក លីម ឆាំងហួត
២- លោក យិន ផលិត
៣- លោក ស៊ុច សារឿន
៤- លោក យឹម សុខេង
៥- លោក សុខ គីមសួគ៌
៦- អ្នកស្រី ម៉ែ ច័ន្ទតិរម្យ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត.១២១២.១០២៤

លេខៈ ៦៧ ៤ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊ុយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកាត់ដីទំហំសរុប ៧.៤៩៤ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ៥.០៨១ ហិកតា និងពីដែនជំរកសត្វព្រៃរនាមដូនសំ ទំហំ ២.៤១៣ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៧.៤៣៤ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកកាស់ក្រឡ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៨ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៨៣៨ ខបប ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំសរុប ៧.៨៩៤ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ៥.០៨១ ហិកតា និងពីដែនជំរកសត្វព្រៃរនាមដូនសំ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ទំហំ ២.៨១៣ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៨៣៤ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជារដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកគាស់ក្រឡ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានទំហំ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៥.០៨១ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ២.៨២១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃសិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ២.២០០ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិក្រាំងស្វាត ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ តាមប្រព័ន្ធកូអរ ដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ ។
- ផ្ទៃដីទំហំ ២.៨១៣ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃរនាមដូនសំ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនូវដីទំហំ ២.១៩០ ហិកតា នៅភូមិអន្លង់មៀន និងដីទំហំ ២៧៣ ហិកតា នៅភូមិសាមគ្គី ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.២៦៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានចំនួនគ្រួសារ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២១០ គ្រួសារ នៅភូមិព្រៃសិន និងចំនួន ៤៥២ គ្រួសារ នៅភូមិក្រាំងស្វាត ឃុំឆ្នាល់មាន់ស្រុកគាស់ក្រឡ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៥៣៩ គ្រួសារ នៅភូមិអន្លង់មៀន និងចំនួន ៦២ គ្រួសារ នៅភូមិសាមគ្គី ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យលេខ ១៩៧ ... ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការកាត់ដីទំហំសរុប ៧.៤៩៤ ហិកតា ដែលក្នុងនោះកាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ៥.០៨១ ហិកតា និងពីដែនដីអភិវឌ្ឍន៍ផ្សេងៗតាមដូនសំរេចព្រះរាជក្រឹត្យលេខ នស/រកត/០៥០៣/២៥១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ដីទំហំ ២.៤១៣ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ចំណែកដីទំហំ ៧.៤៣៤ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ៦០ ហិកតា ត្រូវទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកកោះក្រឡ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង




| ចំនុចនិយាមការ | | | | | |
|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y |
| 1 | 303855 | 1408991 | 20 | 302364 | 1399573 |
| 2 | 304121 | 1408405 | 21 | 302425 | 1400993 |
| 3 | 304460 | 1408372 | 22 | 302491 | 1401879 |
| 4 | 304455 | 1407531 | 23 | 302937 | 1401917 |
| 5 | 305361 | 1407475 | 24 | 303601 | 1402410 |
| 6 | 305839 | 1406195 | 25 | 303067 | 1402633 |
| 7 | 306066 | 1405728 | 26 | 303595 | 1403723 |
| 8 | 305630 | 1405444 | 27 | 304110 | 1403727 |
| 9 | 305589 | 1403649 | 28 | 304011 | 1404170 |
| 10 | 305322 | 1403428 | 29 | 304383 | 1404994 |
| 11 | 306388 | 1402529 | 30 | 302725 | 1404510 |
| 12 | 307028 | 1402426 | 31 | 302455 | 1405169 |
| 13 | 307334 | 1403407 | 32 | 302053 | 1404814 |
| 14 | 309103 | 1403453 | 33 | 301315 | 1405067 |
| 15 | 309103 | 1397948 | 34 | 301291 | 1405590 |
| 16 | 302646 | 1397616 | 35 | 301733 | 1405671 |
| 17 | 300903 | 1398756 | 36 | 302606 | 1407510 |
| 18 | 301955 | 1399087 | 37 | 302632 | 1408716 |
| 19 | 301951 | 1399542 | 38 | 303185 | 1408999 |

**គម្របព្រៃឈើ**

- ព្រៃរបោះ
- ព្រៃស្រោង
- ព្រៃជ្រុងៗ
- ព្រៃពាក់កណ្តាលស្រោង
- ដីមិនមែនព្រៃ
- ព្រំប្រទល់ដីស្នើសុំ
- ព្រំប្រទល់ដីភ្នំ (ផ្ទៃដីភ្នំសរុបចំនួន៦០ហិកតា)

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

ទិន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២

ឧបសម្ព័ន្ធ(២) នៃអនុក្រឹត្យលេខ ១៧៣ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកាត់ដីទំហំសរុប ៧.៤៩៤ ហិកតា ដែលស្ថិតនៅក្នុងតំបន់ព្រៃឈើរបស់រដ្ឋ
ទំហំ ៥.០៨១ ហិកតា និងពីដែនជម្រកសត្វព្រៃ ... នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ដីទំហំ ២.៤១៣ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
ទុកជាដីទំហំ ៧.៤៣៤ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងរៀបចំជាភូមិស្ថាន និងដីទំហំ៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
នៅស្រុកគាស់ក្រឡ និងស្រុករុក្ខគិរី ខេត្តបាត់ដំបង




| ចំនុចនិយាមការ | | | | | |
|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y |
| 1 | 238575 | 1467287 | 20 | 237745 | 1459999 |
| 2 | 238389 | 1467344 | 21 | 236515 | 1459948 |
| 3 | 238091 | 1467351 | 22 | 236702 | 1460119 |
| 4 | 238143 | 1466706 | 23 | 235825 | 1460954 |
| 5 | 237887 | 1466708 | 24 | 235413 | 1460996 |
| 6 | 237945 | 1464884 | 25 | 235415 | 1461288 |
| 7 | 237982 | 1463254 | 26 | 234962 | 1461646 |
| 8 | 237661 | 1463179 | 27 | 235022 | 1461874 |
| 9 | 237351 | 1462909 | 28 | 233925 | 1461919 |
| 10 | 237604 | 1462787 | 29 | 233717 | 1462562 |
| 11 | 237589 | 1462316 | 30 | 233811 | 1463343 |
| 12 | 237425 | 1462329 | 31 | 233782 | 1463814 |
| 13 | 237396 | 1462159 | 32 | 234188 | 1465797 |
| 14 | 237855 | 1461994 | 33 | 235132 | 1466689 |
| 15 | 237735 | 1461717 | 34 | 235725 | 1467676 |
| 16 | 237642 | 1461765 | 35 | 236859 | 1467620 |
| 17 | 236963 | 1460787 | 36 | 237437 | 1467863 |
| 18 | 237202 | 1460440 | 37 | 238529 | 1467843 |
| 19 | 237636 | 1460196 | | | |




កំណត់សម្គាល់

ព្រៃរេចរឹល

ព្រៃស្រោង

ព្រៃជ្រុះស្លឹក

ព្រៃពាក់កណ្តាលស្រោង

ដីមិនមែនព្រៃ

ព្រំប្រទល់ដីស្នើសុំ

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

មិន្ទស័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២



# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧១៨.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ. បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាននិងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

អនុក្រឹត្យនេះមានគោលដៅកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានពីចំនួន ១២៦០ រៀល ក្នុងមួយសន្ទស្សន៍ ទៅចំនួន ១៥២០ រៀល ក្នុងមួយសន្ទស្សន៍ របស់មន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបង្កើនចំនួន ២០ ភាគរយ នៃបៀវត្សសុទ្ធសាធរបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម ជនពិការ ដែលជាអតីតយុទ្ធជន ។

**មាត្រា ២.**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធ ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ តទៅ ។

**មាត្រា ៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៥៧១ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុន គឿកហ្វាទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ ក្បាលដី និងដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ ក្បាលដី នៅស្រុកសន្ទុក ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១០ សុណសធ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៥៧១ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុន ភៀកហ្វា ទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៩៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលរួមមាន៖

-ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១៣៨ គ្រួសារ
-ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន ភៀកហ្វា ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៦១ គ្រួសារ

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ ក្បាលដី និងដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ ក្បាលដី នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...២១៥...ចុះថ្ងៃទី...២៧....ខែ...វិច្ឆិកា......ឆ្នាំ២០១២ ស្តីពីការកាត់ដីសរុបទំហំ ៥៧១ហិកតា ដែលក្នុងនោះកាត់ចេញពីតំបន់ព្រៃឈើឆ្នាំ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុនភឿកហ្វាទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ក្បាលដី និងដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ក្បាលដី នៅស្រុកសន្ទុក ខេត្តកំពង់ធំ




| តារាងនិយាមការចំណុចព្រំដី | | | | | | តារាងនិយាមការចំណុចព្រំដី | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| Projection UTM,Zone48N,Datum WGS84 | | | | | | Projection UTM,Zone48N,Datum WGS84 | | | | | |
| ឧបករណ៍វាស់វែង: GPSMAP62s | | | | | | ឧបករណ៍វាស់វែង: GPSMAP62s | | | | | |
| P-ID | Northing(m | Easthing(m | P-ID | Northing(r | Easthing(m | P-ID | Northing( | Easthing(r | P-ID | Northing(m | Easthing(m |
| 1 | 558428 | 1386248 | 37 | 561187 | 1387667 | 73 | 560381 | 1386438 | 109 | 559864 | 1385595 |
| 2 | 558320 | 1386643 | 38 | 561154 | 1387666 | 74 | 560382 | 1386427 | 110 | 559868 | 1385612 |
| 3 | 558302 | 1386710 | 39 | 561156 | 1387656 | 75 | 560379 | 1386412 | 111 | 559877 | 1385649 |
| 4 | 558138 | 1386935 | 40 | 561171 | 1387592 | 76 | 560371 | 1386405 | 112 | 559878 | 1385654 |
| 5 | 558378 | 1387323 | 41 | 560928 | 1387552 | 77 | 560370 | 1386404 | 113 | 559879 | 1385658 |
| 6 | 558538 | 1387322 | 42 | 560903 | 1387529 | 78 | 560366 | 1386385 | 114 | 559811 | 1385700 |
| 7 | 559412 | 1387320 | 43 | 560885 | 1387446 | 79 | 560365 | 1386364 | 115 | 559675 | 1385783 |
| 8 | 559418 | 1387320 | 44 | 560856 | 1387454 | 80 | 560363 | 1386351 | 116 | 559674 | 1385783 |
| 9 | 559427 | 1387320 | 45 | 560879 | 1387444 | 81 | 560362 | 1386248 | 117 | 559621 | 1385826 |
| 10 | 559562 | 1387323 | 46 | 560911 | 1387408 | 82 | 560363 | 1386220 | 118 | 559625 | 1385848 |
| 11 | 559569 | 1387319 | 47 | 560896 | 1387383 | 83 | 560363 | 1386217 | 119 | 559570 | 1385879 |
| 12 | 559571 | 1387319 | 48 | 560875 | 1387298 | 84 | 560364 | 1386208 | 120 | 559504 | 1385907 |
| 13 | 559573 | 1387381 | 49 | 560865 | 1387276 | 85 | 560363 | 1386187 | 121 | 559482 | 1385917 |
| 14 | 559477 | 1388984 | 50 | 560855 | 1387267 | 86 | 560368 | 1386133 | 122 | 559461 | 1385926 |
| 15 | 559580 | 1388978 | 51 | 560809 | 1387223 | 87 | 560367 | 1386119 | 123 | 559436 | 1385937 |
| 16 | 559581 | 1388978 | 52 | 560760 | 1387188 | 88 | 560366 | 1386079 | 124 | 559423 | 1385943 |
| 17 | 559855 | 1388876 | 53 | 560766 | 1387179 | 89 | 560372 | 1386022 | 125 | 559404 | 1385951 |
| 18 | 560171 | 1388800 | 54 | 560774 | 1387158 | 90 | 560371 | 1386002 | 126 | 559401 | 1385953 |
| 19 | 560262 | 1388759 | 55 | 560778 | 1387150 | 91 | 560375 | 1385959 | 127 | 559398 | 1385953 |
| 20 | 560322 | 1388731 | 56 | 560779 | 1387118 | 92 | 560377 | 1385927 | 128 | 559218 | 1386005 |
| 21 | 560385 | 1388740 | 57 | 560765 | 1387077 | 93 | 560387 | 1385892 | 129 | 559201 | 1386010 |
| 22 | 560602 | 1388772 | 58 | 560756 | 1387084 | 94 | 560394 | 1385865 | 130 | 559102 | 1386003 |
| 23 | 560797 | 1388731 | 59 | 560724 | 1387034 | 95 | 560397 | 1385855 | 131 | 559046 | 1385998 |
| 24 | 560847 | 1388720 | 60 | 560702 | 1387045 | 96 | 560110 | 1386783 | 132 | 559017 | 1385996 |
| 25 | 561219 | 1388857 | 61 | 560679 | 1387045 | 97 | 560422 | 1385785 | 133 | 559016 | 1385996 |
| 26 | 561295 | 1388883 | 62 | 560649 | 1377054 | 98 | 560568 | 1385694 | 134 | 559014 | 1385996 |
| 27 | 561932 | 1388883 | 63 | 560639 | 1386953 | 99 | 560144 | 1385509 | 135 | 559013 | 1385996 |
| 28 | 561737 | 1387865 | 64 | 560577 | 1386962 | 100 | 560115 | 1385498 | 136 | 558970 | 1385994 |
| 29 | 561702 | 1387852 | 65 | 560550 | 1386885 | 101 | 560110 | 1385497 | 137 | 558969 | 1385994 |
| 30 | 561701 | 1387849 | 66 | 560540 | 1386862 | 102 | 560106 | 1385481 | 138 | 558804 | 1386078 |
| 31 | 561687 | 1387846 | 67 | 560507 | 1386784 | 103 | 559952 | 1385541 | 139 | 558804 | 1386078 |
| 32 | 561475 | 1387807 | 68 | 560437 | 1386675 | 104 | 559910 | 1385557 | 140 | 558499 | 1386167 |
| 33 | 561439 | 1387767 | 69 | 560400 | 1386600 | 105 | 559873 | 1385573 | 141 | 558450 | 1386223 |
| 34 | 561401 | 1387744 | 70 | 560385 | 1386557 | 106 | 559873 | 1385574 | 142 | 560525 | 1385374 |
| 35 | 561363 | 1387720 | 71 | 560378 | 1386533 | 107 | 559859 | 1385578 | 143 | 561932 | 1388989 |
| 36 | 561290 | 1387670 | 72 | 560374 | 1386497 | 108 | 559863 | 1385593 | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីសរុបទំហំ ១.២៥៨ ហិកតា ដែលក្នុងនោះ (១) កាត់ចេញពីក្រុមហ៊ុនហ្គោលហ្វៃសិន (២)ពីក្រុមហ៊ុនមេគង្គ និង(៣) ពីដែនជម្រកសត្វព្រៃបឹងពែរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤១៧ គ្រួសារ និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤០៨ គ្រួសារ លើ ៦១៦ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកប្រាសាទសំបូរ និងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១១ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.២៥៨ ហិកតា ដែលក្នុងនោះ (១) ទំហំ ៥៥៨ ហិកតា កាត់ចេញពីក្រុមហ៊ុនហ្គោលហ្វៃសិន (២) ទំហំ ២៥២ ហិកតា ពីក្រុមហ៊ុនមេគង្គ និង (៣) ទំហំ ៤៤៨ ហិកតា ពីដែនជម្រកសត្វបឹងពែរ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ដើម្បីធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកំពង់ធំ ដែលស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១. ផ្ទៃដីទំហំ ៥៥៨ ហិកតា កាត់ចេញពីក្រុមហ៊ុន ហ្គោលហ្វៃសិន សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាជូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

២. ផ្ទៃដីសរុបទំហំ ៣៧៥ ហិកតា ដែលក្នុងនោះ កាត់ចេញពីក្រុមហ៊ុនមេគង្គ ទំហំ ១៧៨ ហិកតា និងពីដែនជម្រកសត្វព្រៃបឹងពែរ ទំហំ ១៩៧ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាជូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

៣. ផ្ទៃដីទំហំ ៣២៥ ហិកតា ដែលក្នុងនោះ កាត់ចេញពីក្រុមហ៊ុន មេគង្គ ទំហំ ៧៤ ហិកតា និងពីដែនជម្រកសត្វព្រៃបឹងពែរ ទំហំ ២៥១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូន

ប្រជាពលរដ្ឋ នៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទី ឧបសម្ព័ន្ធ(៣) នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៥១៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន ហ្គោលហ្វៃសិន ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១០៨ គ្រួសារ នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ

២.ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន មេគង្គ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៩៥ គ្រួសារនិងផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃបឹងពែរ
ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៧៣ គ្រួសារ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក

៣. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុនមេគង្គ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៩ គ្រួសារ និងផ្ទៃដីកាត់ចេញពីដែនជម្រកសត្វបឹងពែរ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៨ គ្រួសារ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក។

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៤០៨ គ្រួសារ លើក្បាលដីចំនួន ៦១៦ ក្បាលដី នៅភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១០៨ គ្រួសារ លើក្បាលដីចំនួន ១៨៥ ក្បាលដី នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៦៨ គ្រួសារ លើក្បាលដីចំនួន ២៤៣ ក្បាលដី នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៣២ គ្រួសារ លើក្បាលដីចំនួន ១៨៨ ក្បាលដី នៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៩៦២-អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **អ៊ុំ ឆាយឆាយ** ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០១២
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៩៧៨ -អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

## ការចុះបញ្ជីដីកសិកម្ម
## សម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម

**ប្រការ ៣៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលដីកសិកម្មសម្រាប់តម្រូវការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មឬមានតម្រូវការសាធារណៈក្នុងវិស័យសិក្សាធិការ ការស្រាវជ្រាវ វិស័យសុខាភិបាល ការធ្វើដល់សាធារណៈ ការតាំងពិព័រណ៍ផ្លូវការ ឬសម្រាប់តម្រូវការប្រើប្រាស់ចុងក្រោយផ្សេងទៀត

ដែលមិនមែនជាការធ្វើពាណិជ្ជកម្មឬចរាចរណ៍លើទីផ្សារ ត្រូវស្នើសុំការចុះបញ្ជីនិងលិខិតអនុញ្ញាតនាំចូលនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុគ្រោះការតម្រូវបមាណីយចំពោះសំណើសុំការចុះបញ្ជីជីកសិកម្មសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម ប៉ុន្តែចាំបាច់ត្រូវផ្តល់ឯកសារប្រភពដើមស្តីពីអត្តសញ្ញាណយថាប្រភេទនៃជីកសិកម្មនោះ រួមមាន៖

- ប្រភេទជីកសិកម្មនិងឈ្មោះពាណិជ្ជកម្ម
- សារជាតុចិញ្ចឹមនៃប្រភេទជីកសិកម្ម
- ឈ្មោះប្រទេស ក្រុមហ៊ុនប្រភពដើមផលិតឬនាំចូលមកកម្ពុជា
- មុខសញ្ញាប្រើប្រាស់និងបរិមាណប្រើប្រាស់ដែលត្រូវស្នើសុំនាំចូល។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាបណ្តោះអាសន្នប្រភេទជីកសិកម្មនោះសម្រាប់តែតម្រូវការប្រើប្រាស់ជាក់លាក់ក្នុងសុពលភាពរយៈពេល១(មួយ)ឆ្នាំប៉ុណ្ណោះ។

**ប្រការ ៣៦.-**

ជីកសិកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ន និងបានអនុញ្ញាតឲ្យនាំចូលសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម មិនអាចធ្វើចរាចរណ៍លើទីផ្សារឬធ្វើការផ្គត់ផ្គង់ចែកចាយជាលក្ខណៈពាណិជ្ជកម្ម និងធ្វើការផ្សាយពាណិជ្ជកម្មបានឡើយ។

ការប្រព្រឹត្តល្មើសនឹងប្រការនេះ ត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**ប្រការ ៣៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសឬមិនគោរពតាមនីតិវិធីនិងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

# ជំពូកទី ១០

# អវសានប្បញ្ញត្តិ

**ប្រការ ៣៨.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣៩.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១២

រដ្ឋមន្ត្រី

ចន់ សារុន

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ ៣៩
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ.៤១៥..........ប្រក.កសក ចុះថ្ងៃទី១៧.ខែ.សីហា..ឆ្នាំ.២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# អត្ថសញ្ញាណនៃប្រភេទជីកសិកម្ម

**ជីកសិកម្ម** សំដៅដល់អង្គធាតុដែលប្រើប្រាស់ក្នុងដី ឬលើរុក្ខជាតិដោយផ្តល់នូវសារជាតុចិញ្ចឹមមួយ ឬច្រើន ដើម្បីជំរុញនូវបណ្តូរកម្មគីមីដែលជួយទ្រទ្រង់ និងធ្វើឲ្យប្រសើរដល់ការលូតលាស់ ឬ ទិន្នផល ទាំងបរិមាណនិងគុណភាពនៃដំណាំ។ សារជាតុចិញ្ចឹមរុក្ខជាតិរួមមាន៖

- សារជាតុចិញ្ចឹមចម្បង៖ N, P, K
- សារជាតុចិញ្ចឹមបន្ទាប់បន្សំ៖ S, Ca, Mg។ល។
- មីក្រូសារជាតុចិញ្ចឹម៖ ដែក(Fe) ម៉ង់កាណែស(Mn) បរ(B) ម៉ូលីបដែន (Mo) ទង់ដែង(Cu) សង្កសី(Zn) ក្លរីន(Cl) កូបាល់(Co)។ល។

ជីកសិកម្ម ត្រូវបានចាត់ថ្នាក់ដូចជា៖

១-ជីអសរីរាង្គឬជីគីមី(Inorganic fertilizer/chemical fertilizer)។

២-ជីសរីរាង្គ(Organic fertilizer)។

៣-ជីជីវសាស្ត្រ(Bio-fertilizer)។

៤-ជីកែលំអគុណភាពដី(Soil conditioner)។

៥-ជីវត្ថុធាតុដើម(Raw Materials)។

**១-ជីអសរីរាង្គឬជីគីមី**(Inorganic/ Chemical fertilizer) សំដៅដល់ជីគីមីដែលមានសារជាតុចិញ្ចឹមចម្បង(N,P,K) និងផ្តល់ដោយសមាសធាតុអសរីរាង្គ(រ៉ែ) ឬសមាសធាតុសំយោគ(គីមី)ដែលមានទម្រង់រឹងឬរាវ និងមានសារជាតុចិញ្ចឹមសំខាន់យ៉ាងតិចចំនួនមួយមុខ សារជាតុចិញ្ចឹមបន្ទាប់បន្សំ និងមីក្រូសារជាតុចិញ្ចឹម។ ជីអសរីរាង្គធម្មតាសំដៅដល់ប្រភេទជីអសរីរាង្គមួយចំនួនដែលធ្លាប់បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបាននិយមប្រើប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ហើយដែលត្រូវបានកំណត់បញ្ជីឈ្មោះដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**២-ជីសរីរាង្គ**(Organic fertilizer) សំដៅដល់ប្រភេទជីដែលមានប្រភពដើមពីផលិតផលរុក្ខជាតិ ឬសត្វដែលឆ្លងកាត់ការបំបែកជាតុតាមរយៈដំណើរការជីវសាស្ត្រ គីមីសាស្ត្រ ឬដំណើរការផ្សេងទៀតដែលធ្វើឲ្យរូបធាតុដើមប្រែក្លាយដូចទម្រង់ដូចដី គ្មានភ្នាក់ងារចម្លងជំងឺ និងរក្សានូវសារជាតុសរីរាង្គមិនតិចជាង២០%(Organic Matter "OM") និងអាចផ្តល់សារជាតុចិញ្ចឹមដល់រុក្ខជាតិ ឬដំណាំ។ ជីសរីរាង្គរួមមាន៖ ជីសរីរាង្គធម្មតា ជីកំប៉ុស្ត៍ និងជីសរីរាង្គសម្បូណ៌ដែលមានសារជាតុចិញ្ចឹមសរុប NPK ពី ៣-៨% ឬលើស។

**៣-ជីជីវសាស្ត្រ**(Bio-fertilizer) សំដៅដល់ប្រភេទជីកសិកម្មដែលក្នុងនោះមានសារជាតុសកម្ម

ជីវសាស្ត្រជាមីក្រូសពាង្គកាយដែលអាចចាប់យក(Fixation)និងជំរុញសារធាតុសំខាន់ណាមួយដែលមានស្រាប់នៅក្នុងបរិយាកាស ឬដី ឬជំរុញការបំបែកជាតុសារធាតុសរីរាង្គនិងសំណល់រុក្ខជាតិឬសត្វ ដើម្បីបង្កើតបានជាសារធាតុចិញ្ចឹមសម្រាប់ទ្រទ្រង់ការលូតលាស់របស់រុក្ខជាតិ ឬដំណាំ។

ជីជីវសាស្ត្រត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

- ជីមីក្រូជីវសាស្ត្រ(Microbial Inoculants) សំដៅដល់ផលិតផលជីវសាស្ត្រសកម្ម ដែលមានសារព័ន្ធ(Population)នៃខ្សែស្រឡាយសកម្មមួយ ឬចម្រុះនៃបាក់តេរី អាកទីណូមីសេត ស្លែ ឬផ្សិត ដែលមានប្រយោជន៍ក្នុងសកម្មភាពជីវសាស្ត្រផ្សេងៗ ដូចជាការចាប់យកអាសូត(N-Fixation) ឬការបំបែកជាតុនៃសត្វ សំណល់សរីរាង្គ និងភាពរលាយនៃសារជាតុចិញ្ចឹមខ្លះៗពីដីដូចជាហ្វូស្វ័រ(P)។ ឧទាហរណ៍៖ ប្រភេទជី Micro fix, Nitro plus, Rhyzobium។ល។
- ជីបំបែកជាតុ(Decomposers) សំដៅដល់ជីជីវសាស្ត្រដែលសារជាតុជីវសាស្ត្រសកម្ម មានមីក្រូសរីរាង្គ ដែលជំរុញការបំបែកជាតុនៃកាកសំណល់រុក្ខជាតិឬសត្វទៅជាជីសរីរាង្គ ជីកំប៉ុស្ត៍ ឬជីកែលំអគុណភាពដី(ឧទាហរណ៍៖ ជីEM ដែលត្រូវបានប្រើប្រាស់ដោយប្រទេសមួយចំនួន)។

**៤- ជីកែលំអគុណភាពដី**(Soil Conditionner) សំដៅដល់រូបជាតុសរីរាង្គធម្មជាតិ ឬសំយោគ ឬអសរីរាង្គដែលកែប្រែលក្ខណៈរូបវន្តរបស់ដី ដូចជារចនាសម្ព័ន្ធ សមត្ថភាពរក្សាសំណើម សមត្ថភាពរីករួម ឬភាពធន់ទៅនឹងការប្រេះក្រហែង និងធ្វើឲ្យប្រសើរលក្ខខណ្ឌជីវសាស្ត្រនិងគីមីសាស្ត្ររបស់ដី (ឧទាហរណ៍៖ ជីកំបោរ ជីល្បាប់។ល។)។

**៥- ជីវត្ថុធាតុដើម**(Raw Materials) សំដៅដល់រូបជាតុសរីរាង្គឬអសរីរាង្គដែលប្រើប្រាស់នៅក្នុងផលិតកម្មជីពាក់កណ្តាលសម្រេចឬផលិតផលជីសម្រេច រួមមានរ៉ែធម្មជាតិ(ថ្មហ្វូស្វាត ថ្មកំបោរ ម្នាងសិលា កំណាស៊ុលហ្វួរ។ល។) និងកំណផ្សេងទៀតនៅក្នុងរ៉ែធម្មជាតិដែលត្រូវបានរុករក និងប្រើប្រាស់ក្នុងផលិតកម្មជី។

-----ៜ-ៜ-ៜ✵ៜ-ៜ-ៜ-----

ឧបសម្ពន្ធទី២នៃប្រកាសលេខ..២១៥.........ប្រក.កសក ចុះថ្ងៃទី.១៧..ខែ.សីហា..ឆ្នាំ.២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# សេចក្តីអះអាងព័ត៌មាននិងទិន្នន័យស្តីពីជីកសិកម្មដែលស្នើសុំការចុះបញ្ជី

CLARIFICATION INFORMATION AND DATA FOR THE APPLICATION OF FERTILIZER REGISTRATION

## I- ព័ត៌មានទូទៅស្តីពីផលិតផល (Information on the products)

១-ប្រភេទជីកសិកម្មឬយថាប្រភេទ (Type/ Specification of fertilizer) ........................................

២-ទម្រង់លក្ខណៈ (Characteristic)៖

- លក្ខណៈរូប (Physical feature)..............................................................................
- លក្ខណៈគីមី (Chemical feature)............................................................................

៣-សមាសធាតុធានា/អះអាង (Guaranteed/ Declared Composition)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៤-វិញ្ញាបនបត្របញ្ជាក់បមាណីយធានាពីប្រទេសប្រភពដើមផ្គត់ផ្គង់៖

(Certificate of Guaranteed Analysis from supplier/ country of origin)

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

-លទ្ធផលវិភាគសមាសធាតុចេញដោយមន្ទីរពិសោធន៍ជាតិឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់៖

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

៥-ប្រភេទនិងទំហំសំបកវេចខ្ចប់ (Type/ Size of packing)...................................................

..........................................................................................................................

៦-ទម្ងន់និងចំណុះផលិតផលក្នុងសំបកវេចខ្ចប់ (Net weight/ capacity of product)

..........................................................................................................................

៧-គំរូសំបកវេចខ្ចប់ (Sample of package) ៖ -មានភ្ជាប់ ☐................ -គ្មានភ្ជាប់ ☐..............

៨-សេចក្តីសង្ខេបស្តីពីដំណើរការលាយផ្សំ (Description on the production process)

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

៩-ប្រភពនិងប្រភេទវត្ថុធាតុដើម (Source and kind of raw materials)..............................

..........................................................................................................................

១០-ដំណាំគោលដៅត្រូវប្រើ (Target Crops) .......................................................................

..........................................................................................................................

..........................................................................................................................

## II- សំណាកផលិតផល (Sample of products)

១-សំណាកសម្រាប់វិភាគ៖ ចំនួន .......................... សំណាក/បរិមាណ ៖.................................

២-សំណាកសម្រាប់សាកល្បងជីវប្រសិទ្ធភាព៖ ចំនួន.......... សំណាក/បរិមាណ ៖.............................

៣-វិធីសាស្ត្រវិភាគ ( Method of Analysis ) ..............................................................................

..............................................................................................................................

៤-ស្ថានីយ/អ្នកស្រាវជ្រាវដែលធ្វើការសាកល្បងលើទីវាលពិសោធន៍ ( Station/ Researcher handling experimentation field test ) ..............................................................................

..............................................................................................................................

..............................................................................................................................

៥-ទិន្នន័យសាកល្បងភ្នាក់ងារចម្លងជំងឺ ( Test of Pathogens )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

៦-ទិន្នន័យសាកល្បងលោហៈធ្ងន់ ( Test for Heavy Metal )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

៧-ទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ ( Test for weeds seeds and insects )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

III- **ស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ** ( Label in Khmer )

១-ចំពោះជីទឹក ( For liquid fertilizer )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

២-ចំពោះជីគោក ( For solid fertilizer )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

IV-**ព្រឹត្តិបត្របច្ចេកទេសនៃជីកសិកម្មចេញពីប្រទេសប្រភពដើម** ( Brochure on technical specification from the country of origin )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

V- **ទិន្នន័យជីវប្រសិទ្ធភាព**"ចេញពីប្រទេសប្រភពដើម" ( Bio-efficacy from the country of origin )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

VI-**លទ្ធផលសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍** "ចេញដោយស្ថានីយពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ( Results on Bio-efficacy test at field trial station )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

VII-**របាយការណ៍ពិនិត្យ វាយតម្លៃទីតាំង និងដំណើរការលាយផ្សំ** "សម្រាប់ផលិតកម្មក្នុងស្រុក" ( Report on formulation process and location assesements )

☐-មានភ្ជាប់.................................. ☐-គ្មានភ្ជាប់..................................

VIII- **សេចក្តីបញ្ជាក់អះអាង** ( Certification / clarification )

ខ្ញុំសូមបញ្ជាក់អះអាងថារាល់ព័ត៌មាននិងឯកសារជូនភ្ជាប់ទាំងអស់រួមទាំងឧបសម្ពន្ធភ្ជាប់សម្រាប់ស្នើសុំការចុះបញ្ជីដីកសិកម្មខាងលើ គឺពិតនិងត្រឹមត្រូវប្រាកដមែន។

ដើម្បីជាសក្ខីភាពពេលនេះ ខ្ញុំសូមចុះហត្ថលេខាជាកស្តុតាងនៅកាលបរិច្ឆេទដូចខាងក្រោមៈ

I HEREBY certify that the foregoing data information including those in the annexes hereof are true and correct.

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ..............ឆ្នាំ ២០.........ម៉ោង.............................

Phnom Penh, Day..............................................Time.............................

**ហត្ថលេខានិងត្រា**

**នាយកគ្រប់គ្រងក្រុមហ៊ុន**

( Name and Signature / Stamp of director company )

ឧបសម្ពន្ធទី៣នៃប្រកាសលេខ..៤១៥..........ប្រក.កសក ចុះថ្ងៃទី១៧..ខែ.សីហា..ឆ្នាំ..២០១២
"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# បមាណីយយថាប្រភេទនៃក្រុមជីសរីរាង្គ

## SPECIFICATION STANDARD FOR OGRANIC FERTILIZER

## ក-បមាណីយយថាប្រភេទ

| លក្ខណៈវិនិច្ឆ័យ | ក្រុមជីសរីរាង្គ |
|---|---|
| ១-បរិមាណ NPK (N+P+K) | ៣-៨ % ឬលើស |
| ២-ផលធៀប C:N | ១២ : ១ |
| ៣-សំណើម | ≤ ៣៥ % |
| ៤-សារធាតុសរីរាង្គ (OM) | ≥ ២០ % |
| ៥-pH | ៧-៨ |

## ខ-កម្រិតអនុគ្រោះនៃលោហៈធ្ងន់

| យថាប្រភេទលោហៈធ្ងន់ | កម្រិតអនុគ្រោះអតិបរមា (mg/ kg នៃទម្ងន់ស្ងួត) |
|---|---|
| ១-ស័ង្កសី (Zn) | ១០០០ |
| ២-សំណ (Pb) | ១០០ |
| ៣-ទង់ដែង (Cu) | ៣០០ |
| ៤-ក្រូម (Cr) | ៥០ |
| ៥-នីកែល (Ni) | ៥០ |
| ៦-បារត (Hg) | ០.១៥ |
| ៧-កាដមីញ៉ូម"Cadmiun" (Cd) | ៥ |
| ៨-កូបាល់ (Co) | ១៥០ |
| ៩-ម៉ូលីបដែន (Mo) | ២០ |
| ១០-អាសេនិច ($As_2O_3$) | ១០ |

## គ-ភ្នាក់ងារចម្លងជំងឺ

| | |
|---|---|
| ១-Fecal Streptococci | < ៥.១០$^{៣}$ /g compost |
| ២-Total Coliforms | < ៥ .១០$^{២}$ /g compost |
| ៣-Salmonella | ០ |
| ៤-Infective parasitic | ០ |

## ឃ-សម្រង់ទត្តមាននៃស្មៅចង្រៃ

| ប្រភេទស្មៅចង្រៃ | ដង់ស៊ីតេ (No/$m^2$) | | ទម្ងន់ (g/$m^2$) | |
|---|---|---|---|---|
| | ៣០ ថ.ក.ស្ទ | ៦០ ថ.ក.ស | ៣០ ថ.ក.ស្ទ | ៦០ ថ.ក.ស |
| ១-ពពួកស្មៅ | | | | |
| ២-ពពួករុក្ខជាតិស្លឹកធំ | | | | |
| ៣-កក់ | | | | |

***កំណត់សម្គាល់:***

*-ថ.ក.ស្ទ: ចំនួនថ្ងៃក្រោយពេលស្ទូង*

*-ថ.ក.ស: ចំនួនថ្ងៃក្រោយពេលសាប*

ឧបសម្ពន្ធទី៤នៃប្រកាសលេខ៤១៥............ប្រក.កសក ចុះថ្ងៃទី១៧..ខែ.សីហា..ឆ្នាំ..២០១៧

"ស្ដីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# ប្រភេទជីអសរីរាង្គធម្មតា

| ល.រ | យថាប្រភេទតាមក្រុមប្រភេទជី | សារធាតុចិញ្ចឹមចម្បង | | | មីក្រូសារធាតុ និងសារធាតុ ចិញ្ចឹមផ្សេងទៀត |
|---|---|---|---|---|---|
| | | N | P | K | |
| | ក-ក្រុមជីអាហ្សូត (Straight Nitrogenous Group) | | | | រាល់ប្រភេទជីអសរីរាង្គ ដែលលាយផ្សំដោយមីក្រូ សារធាតុនិងសារធាតុ បំប៉នផ្សេងទៀត(TE) ត្រូវធ្វើងកាត់ការសាកល្បង ជីប្រសិទ្ធភាពលើទីវាល ពិសោធន៍ |
| ១ | UREA | ៤៦ | ០ | ០ | |
| ២ | Ammonium Sulphate | ២១ | ០ | ០ | |
| ៣ | Ammonium Chloride | ២៥ | ០ | ០ | |
| ៤ | Ammonia (Any drous) | ៨២ | ០ | ០ | |
| | ខ-ក្រុមជីហ្វូស្វាត (Straight Phosphatic Group) | | | | |
| ៥ | Single Super Phosphate(SSP) | ០ | ១៦ | ០ | |
| ៦ | Triple Super Phosphate (TSP) | ០ | ៤៦ | ០ | |
| ៧ | Ordinary Superphosphate(OSP) | ០ | ២០ | ០ | |
| ៨ | Rock Phosphate (RP) | | | | |
| | គ-ក្រុមជីប៉ូតាស (Straight Potassic Group) | | | | |
| ៩ | Muriate of Potash (MOP) | ០ | ០ | ៦០ | |
| ១០ | Potassium Chloride | ០ | ០ | ៦០ | |
| ១១ | Sulfate of Potash (SOP) | ០ | ០ | ៥០ | |
| | ឃ-ក្រុមចម្រុះ NP (N,P Complex Group) | | | | |
| ១២ | Diamonium Phosphate(DAP) | ១៨ | ៤៦ | ០ | |
| ១៣ | Ammonium Phosphate Sulphate | ១៦ | ២០ | ០ | |
| ១៤ | Ammonium Phosphate Sulphate | ២០ | ២០ | ០ | |
| | ង-ក្រុមចម្រុះ N.P.K (N,P,K Complex Group) | | | | |
| ១៥ | Triple 15 | ១៥ | ១៥ | ១៥ | |
| ១៦ | Triple 17 | ១៧ | ១៧ | ១៧ | |
| ១៧ | Triple 20 | ២០ | ២០ | ២០ | |
| ១៨ | NPK | ១៦ | ១៦ | ៨ | |
| ១៩ | NPK | ២០ | ២០ | ១៥ | |
| ២០ | NPK | ១៥ | ៣០ | ១៥ | |
| ២១ | ប្រភេទជីNPK ចម្រុះធម្មតាផ្សេងទៀតដែល គ្មានមីក្រូសារជាតុ ឬសារជាតុចិញ្ចឹមផ្សេងទៀត(TE) | | | | |

ឧបសម្ពន្ធទី៥នៃប្រកាសលេខ ៤១៥ ..........ប្រក.កសក ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១២

"ស្ដីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# គំរូស្លាកសញ្ញាព័ត៌មានជីកសិកម្ម

## ក-ប្រភេទជីទឹក

### ផ្នែកកណ្ដាលសំបកវេចខ្ចប់(មុខ)

**ឈ្មោះផលិតផល**

**រូបមន្ដផលិតផល**

រូបសញ្ញា/ ពាណិជ្ជសញ្ញា

លេខបញ្ជិការបស់ MAFF........................

លេខឡូត៍..........................................

កាលបរិច្ឆេទផលិត/សុពលភាព................

ចំណុះ..........

### ផ្នែកចំហៀងសំបកវេចខ្ចប់(ឆ្វេង)

សន្និធិនិងការបោះចោល

..........................................

..........................................

..........................................

..........................................

ភាពត្រូវគ្នាជាមួយសារធាតុផ្សេងទៀត

..........................................

..........................................

..........................................

..........................................

ការហាមឃាត់

..........................................

..........................................

..........................................

..........................................

ការធានា

..........................................

..........................................

..........................................

ក្មេងៗរក្សាទុកពីដៃក្មេង

### ផ្នែកកណ្ដាលសំបកវេចខ្ចប់(ក្រោយ)

**របៀបប្រើប្រាស់៖**

..........................................

..........................................

| ដំណាក់ | ពេលវេលាប្រើប្រាស់ | រយៈពេលមុនប្រមូលផល | កម្រិតប្រើប្រាស់ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ផ្នែកចំហៀងសំបកវេចខ្ចប់(ស្ដាំ)

**ព័ត៌មានស្ដីពីផលិតផល**

សារធាតុចិញ្ចឹម.......................... (ភាគរយ)

-

-

-

មីក្រូសារធាតុ.............................. (ភាគរយ)

-

-

-

-

**ព័ត៌មានផ្សេងទៀត**

..........................................

..........................................

..........................................

ផលិតដោយក្រុមហ៊ុន/ប្រទេស......

..........................................

នាំចូលនិងផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយ

ក្រុមហ៊ុន..........................................

អាសយដ្ឋាន..........................................

ទូរស័ព្ទ/ទូរសារ /អ៊ីម៉ែល...............................

២៧/៣៥

## ខ-ប្រភេទជីគោក

**ឈ្មោះផលិតផល**

សារធាតុចិញ្ចឹម ៖ មីក្រូសារធាតុ %

(N) ៖........................ ...............................

(P) ៖........................ ...............................

(K) ៖........................ ...............................

រូបសញ្ញា/ ពាណិជ្ជសញ្ញា

លេខបញ្ជិការរបស់ MAFF.........................................

លេខឡូត៍...................................................................

កាលបរិច្ឆេទផលិត/សុពលភាព...............................

**ទម្ងន់....**

**របៀបប្រើប្រាស់ ៖**

...........................................................................................

...........................................................................................

| ដំណាំ | ពេលវេលាប្រើប្រាស់ | កម្រិតប្រើប្រាស់ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

ផលិតដោយក្រុមហ៊ុន/ប្រទេស..................................

...........................................................................

នាំចូលនិងផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយក្រុមហ៊ុន........................................

អាសយដ្ឋាន...........................................................

...........................................................................

ទូរសព្ទ/ទូរសារ /អ៊ីម៉ែល..........................................

ផ្នែកខាងមុខ ផ្នែកខាងខ្នង

ឧបសម្ពន្ធទី៦នៃប្រកាសលេខ...៤១៥.........ប្រក.កសក ចុះថ្ងៃទី.២៧.ខែ.សីហា..ឆ្នាំ.២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្ម

## THE APPLICATION FOR REGISTRATION, ANALYSIS AND BIO-EFFICACY TEST OF FERTILIZER

## I- ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ (General Information on the Applicant)

១-ឈ្មោះអ្នកស្នើសុំ(Name of Applicant)....................................................ភេទ (Sex)........

២-សញ្ជាតិ(Nationality)........................................................................................

៣-អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន (ID/ Passport)លេខ ....................ផុតកំណត់ថ្ងៃទី.............

៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន(Company/Private legal person)..........................................

☐-នាំចូលនាំចេញ(Import-Export) ☐-ផលិតឬលាយផ្សំ(Manufacturer/ Formulator)

☐-វេចខ្ចប់ជាថ្មី(Repacker) ☐-ផ្គត់ផ្គង់ចែកចាយ(Distributor)

៥-អាសយដ្ឋានក្រុមហ៊ុននៅកម្ពុជា (Company Address in Cambodia)...................................

..........................................................................................................................

ទូរសព្ទឬទូរសារ (Phone/ Fax)..................................................................................

គេហទំព័រ(Home Page)..........................................................................................

៦-ចុះបញ្ជីពាណិជ្ជកម្ម (Trade Registration)...........................................................

៧-ទីតាំងគ្រឹះស្ថានផលិត (Location of Production plant).............................................

..........................................................................................................................

ទូរសព្ទឬទូរសារ (Phone/ Fax)..................................................................................

៨-ឃ្លាំងសន្និធិ លេខចុះបញ្ជី និងទីតាំង (warehouse/ Registration number and location)...........

..........................................................................................................................

..........................................................................................................................

៩-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ"បើសិនជាមាន"(Certificate from mother company).....................

..........................................................................................................................

១០-ក្រុមហ៊ុនផ្គត់ផ្គង់និងប្រទេសប្រភពដើមផលិតឬលាយផ្សំ ផ្គត់ផ្គង់ឬនាំចេញ (Company Supplier/ country of origin)..........................................................................................

អាសយដ្ឋាន:...........................................................................................................

ទូរសព្ទឬទូរសារ(Phone/ Fax)..................................................................................

គេហទំព័រ(Home Page)..........................................................................................

## II- គោលបំណងនិងលក្ខណៈនៃសំណើ (Purpose and state of Registration)

☐-ការចុះបញ្ជី ☐-ការធ្វើវិភាគ ☐-ការសាកល្បងជីវប្រសិទ្ធភាព

☐-សម្រាប់គោលបំណងពាណិជ្ជកម្ម

☐-សម្រាប់គោលបំណងមិនមែនពាណិជ្ជកម្ម /ប្រើប្រាស់ជាក់លាក់

☐-ការចុះបញ្ជីថ្មី

☐-បន្តការចុះបញ្ជីជាថ្មី

| **សម្រាប់នាយកដ្ឋានគតិយុត្តកសិកម្មតែប៉ុណ្ណោះ** (For Department Agricultural Legistration use only) |
|---|
| សំណុំឯកសារស្នើសុំលេខ៖......................................កាលបរិច្ឆេទទទួល៖......................<br>វិក្កយបត្របង់ប្រាក់សេវាកម្មធ្វើវិភាគសំណាក៖ លេខ..............................................................<br>វិក្កយបត្របង់ប្រាក់សេវាកម្មធ្វើការសាកល្បង៖ លេខ...........................................................<br>បញ្ជិកាចុងក្រោយបានទទួល(បើមាន)៖ លេខ..............................................................<br>កាលបរិច្ឆេទផុតសុពលភាព៖....................................................................................<br>សំណាកសម្រាប់វិភាគ៖...........................................................................................<br>សំណាកសម្រាប់ការសាកល្បងជីវប្រសិទ្ធភាព៖..........................................................<br>វិក្កយបត្របង់ប្រាក់សេវាកម្មសម្រាប់ការចុះបញ្ជីលើកនេះ៖ លេខ..........................................<br>កំណត់សម្គាល់៖...................................................................................................... |

### III- **យថាប្រភេទជីកសិកម្មដែលស្នើសុំការចុះបញ្ជី**

(Specification of fertilizers to be registered)

| ល.រ<br>No | យថាប្រភេទ<br>Specification | ចំណាត់ថ្នាក់ប្រភេទជី<br>Fertilizer Class | ឈ្មោះពាណិជ្ជកម្ម<br>Trade name | ប្រទេសប្រភពដើមផលិត<br>Country of origin | ប្រទេសប្រភពដើមវេចខ្ចប់ជាថ្មី/នាំចេញ<br>Country of re-packaging / Exporting origin |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| សរុបត្រឹមចំនួន:..................មុខ<br>Total items: ......................Items | | | | | |

### IV- **សំណុំឯកសារត្រូវភ្ជាប់** (documents to be attached)

១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ច្បាប់ថតចម្លង)........................................................ ០១ច្បាប់

២- សេចក្តីអះអាងព័ត៌មាននិងទិន្នន័យស្តីពីជីកសិកម្មដែលស្នើសុំការចុះបញ្ជី(តាមយថាប្រភេទនីមួយៗ) ០១ច្បាប់

៣- វិញ្ញាបនបត្របញ្ជាក់បមាណីយជានាពីប្រទេសប្រភពដើមផលិត/នាំចេញ .......................... ០១ច្បាប់

៤- លទ្ធផលវិភាគសមាសធាតុចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្មឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........................ ០១ច្បាប់

៦- លទ្ធផលវិភាគភ្នាក់ងារចម្លងជំងឺ ........................ ០១ច្បាប់

៧- លទ្ធផលវិភាគសារធាតុលោហៈធ្ងន់ ........................ ០១ច្បាប់

៨- លទ្ធផលសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ ........................ ០១ច្បាប់

៩- គំរូស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ........................ ០១ច្បាប់

១០- គំរូសំបកវេចខ្ចប់ ........................ ០១ច្បាប់

១១- ទិន្នន័យជីវប្រសិទ្ធភាពពីប្រភពដើមលាយផ្សំ ........................ ០១ច្បាប់

១២- លទ្ធផលសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ........................ ០១ច្បាប់

១៣- សេចក្តីសង្ខេបស្តីពីដំណើរការផលិតឬលាយផ្សំចេញពីប្រភពដើម ........................ ០១ច្បាប់

១៤- របាយការណ៍ពិនិត្យនិងវាយតម្លៃទីតាំងនិងដំណើរការលាយផ្សំ(សម្រាប់ផលិតកម្មក្នុងស្រុក) ០១ច្បាប់

១៥- ព្រឹត្តិបត្របច្ចេកទេសស្តីពីប្រភេទជីកសិកម្មនីមួយៗ(ចេញពីប្រភពដើមផលិតឬលាយផ្សំ).... ០១ច្បាប់

១៦- CD soft copy នៃបញ្ជីឈ្មោះជីកសិកម្មដែលស្នើសុំការចុះបញ្ជី គំរូស្លាកសញ្ញាព័ត៌មាន និងឯកសារយថាប្រភេទបច្ចេកទេសផ្សេងទៀត ........................ចំនួន០១។

**កំណត់សម្គាល់៖**

១- រាល់ឯកសារភ្ជាប់ជាច្បាប់ថតចម្លងដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រគ្រប់ប្រភេទឬឯកសារចាំបាច់ផ្សេងទៀតត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២- ក្នុងករណីក្រុមហ៊ុនចាត់តាំងបុគ្គលិករបស់ខ្លួន ឬអ្នកតំណាងក្រុមហ៊ុនរបស់ខ្លួនដើម្បីទទួលខុសត្រូវក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ នាយកក្រុមហ៊ុនត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ក្រុមហ៊ុន ដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។

**V- សំណើសុំ**

ខ្ញុំបាទ/នាងខ្ញុំជានាយកក្រុមហ៊ុនសូមគោរពស្នើសុំធ្វើវិភាគ ការសាកល្បងជីវប្រសិទ្ធភាព និងចុះបញ្ជិកាជីកសិកម្ម ដែលមានព័ត៌មាន សំណាក និងឯកសារភ្ជាប់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើសំណើសុំការចុះបញ្ជីជីកសិកម្មខាងលើដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី.........ខែ..............ឆ្នាំ..........

**ប្រធានក្រុមហ៊ុនឬនាយកគ្រប់គ្រង**

**ហត្ថលេខានិងត្រា**

ឧបសម្ពន្ធទី៧នៃប្រកាសលេខ..៤១៥.........ប្រក.កសក ចុះថ្ងៃទី១៧ខែ..សីហា..ឆ្នាំ២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# ការតម្រូវឯកសារស្តីពីទិន្នន័យនិងព័ត៌មានសម្រាប់ការចុះបញ្ជីជីកសិកម្ម

## REQUIREMENTS OF DOCUMENTS ON DATA & INFORMATION FOR THE REGISTRATION OF FERTILIZER

| ការតម្រូវទិន្នន័យនិងព័ត៌មាន | ប្រភេទជីកសិកម្ម | | | | | |
|---|---|---|---|---|---|---|
| | ជីអសរីរាង្គ ប្រភេទធម្មតា | ជីអសរីរាង្គ ប្រភេទថ្មី | ជីសរីរាង្គ | ជីជីវសាស្ត្រ | ជីកែលំអគុណភាពដី | ជីវត្ថុធាតុដើម |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
| **១-ព័ត៌មានទូទៅ** | | | | | | |
| ១.១-នាមនិងអាសយដ្ឋានរបស់អ្នកស្នើសុំ | ត | ត | ត | ត | ត | ត |
| ១.២-ឈ្មោះនិងពាណិជ្ជសញ្ញានៃផលិតផល | ត | ត | ត | ត | ត | ត |
| ១.៣-ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់និងប្រទេសប្រភពដើមផលិតឬលាយផ្សំ និងផ្គត់ផ្គង់ | ត | ត | ត | ត | ត | ត |
| ១.៤-បមាណីយជានានៃសមាសធាតុឬសារធាតុចិញ្ចឹមដែលអះអាងដោយភ្ជាប់នូវវិញ្ញាបនបត្របញ្ជាក់បមាណីយជានានៃជីកសិកម្ម ដែលចេញពីប្រទេសប្រភពដើមផលិតឬនាំចេញ | ត | ត | ត | ត | ត | ត |
| ១.៥-លទ្ធផលវិភាគសមាសធាតុចេញពីមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ត | ត | ត | ត | ត | ត |
| ១.៦-ប្រភេទ និងទំហំសំបកវេចខ្ចប់ | ត | ត | ត | ត | ត | ត |
| ១.៧-ប្រភពនិងប្រភេទវត្ថុធាតុដើម | ត | ត | ត | ត | ត | ត |
| ១.៨-សេចក្តីសង្ខេបស្តីពីដំណើរការផលិតឬលាយផ្សំ ចេញពីប្រភពដើមផលិតផល | ត | ត | ត | ត | ត | ត |
| **២-សំណាកនៃផលិតផល** | | | | | | |
| ២.១-សំណាកយកចេញពីគំនរឬឡូត៍តែមួយ ចំនួន២សំណាក ចំពោះ៖<br>**ជីសរីរាង្គ:** ៥០០ក្រាម-១គ.ក្រ/១សំណាក | ត | ត | ត | ត | ត | ត |



ហត្ថលេខា

| | | | | | | |
|---|---|---|---|---|---|---|
| ជីអសរីរាង្គៈ ២៥០ក្រាម-១ គ.ក្រ/១សំណាក<br>ជីទឹកៈ ២៥០មិល្លីម៉ែត្រ-១លីត្រ/១សំណាក<br>ជីជីវសាស្ត្រៈ ២សំណាកដែលមាន២០០ក្រាម ឬ២០០ មិល្លីលីត្រ/១សំណាក។ | | | | | | |
| ២.២-វិធីសាស្ត្រវិភាគសមាសធាតុជីកសិកម្ម | ត | ត | ត | ត | ត | ត |
| ២.៣-ទិន្នន័យវិភាគភ្នាក់ងារចម្លងជំងឺ | ម.ត | ម.ត | ត | ត | ម.ត | ត |
| ២.៤-ទិន្នន័យវិភាគលោហៈធ្ងន់ | ត | ត | ត | ម.ត | ម.ត | ត |
| ២.៥-ទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ | ម.ត | ម.ត | ត | ម.ត | ម.ត | ម.ត |
| ៣-ស្លាកសញ្ញា | | | | | | |
| ៣.១-សម្រាប់ជីទឹកឬជីបាញ់ស្លឹក | ត | ត | ត | ត | ត | ត |
| ៣.២-សម្រាប់ប្រភេទជីគោក | ត | ត | ត | ត | ត | ត |
| ៤- ព្រឹត្តិបត្របច្ចេកទេស | ម.ត | ត | ត | ត | ត | ម.ត |
| ៥-ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រភពដើមផលិតឬលាយផ្សំ | ម.ត | ត | ត | ត | ត | ត |
| ៦-លទ្ធផលសាកល្បងជីវប្រសិទ្ធិភាពលើទីវាលពិសោធន៍អនុវត្តដោយស្ថានីយពិសោធន៍កសិកម្ម ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ម.ត | ត | ត | ត | ត | ត |
| ៧-របាយការណ៍ពិនិត្យវាយតម្លៃ ទីតាំងនិងដំណើរការលាយផ្សំ (សម្រាប់ផលិតកម្មក្នុងស្រុក) | ត | ត | ត | ត | ត | ត |

<u>កំណត់សម្គាល់</u>

ត ៖ តម្រូវការព័ត៌មានសម្រាប់ការពិនិត្យនិងវាយតម្លៃ

ម.ត ៖ មិនតម្រូវការព័ត៌មានសម្រាប់ការពិនិត្យនិងវាយតម្លៃ។

ឧបសម្ព័ន្ធទី៨នៃប្រកាសលេខ...៤១៥...........ប្រក.កសក ចុះថ្ងៃទី២៧..ខែ..វិច្ឆិកា..ឆ្នាំ..២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# គំនូសបំព្រួញស្តីពីដំណើរការនៃការចុះបញ្ជីជីកសិកម្ម



ឧបសម្ពន្ធទី៩នៃប្រកាសលេខ..៤១៤............ប្រក.កសក ចុះថ្ងៃទី២៧..ខែ..វិ.ឆា.ឆ្នាំ២០១២
"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម"

# គំរូវិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**លេខ** **កសក.ននក.បជ** រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ.............ឆ្នាំ.........

## វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្ម
## FERTILIZER REGISTRATION CERTIFICATE

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**សូមបញ្ជាក់ថា**

**អ្នកស្នើសុំការចុះបញ្ជី** (Registrant) :...............................................
**អាសយដ្ឋានបច្ចុប្បន្ន**( Address) :...............................................
**ត្រូវបានផ្តល់បញ្ជិកាជីកសិកម្ម** (Registration number) **លេខ**.....................................
**ប្រភេទបញ្ជិកា** (Type of registration) :...............................................
**ប្រភេទជីកសិកម្ម**(Type of fertilizer) :...............................................
**ឈ្មោះពាណិជ្ជកម្ម** (Trade name) :...............................................
**ពាណិជ្ជសញ្ញា** (Trade mark) :...............................................
**សារធាតុចិញ្ចឹមចម្បង** (Primary nutrients): ...............................................
**សារធាតុចិញ្ចឹមបន្ទាប់បន្សំនិងមីក្រូសារធាតុ** (Secondary and Micro-nutrients) ..............................
...............................................................................................
**លក្ខណៈរូប** (Physical properties) : ...............................................
**លក្ខណៈគីមី**(Chemical properties) : ...............................................
**ប្រើប្រាស់សម្រាប់**(For use on) : ...............................................
**ក្រុមហ៊ុននិងប្រទេសផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី**((Manufactured/Formulated/Repackage company/Country)
...............................................................................................

**សិទ្ធិលើទិន្នន័យ** (Right on data) : មានសុពលភាពត្រឹមថ្ងៃទី.................................................។

វិញ្ញាបនបត្រនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំការចុះបញ្ជីដើម្បីប្រើប្រាស់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន និងមានសុពលភាពត្រឹមថ្ងៃទី...........ខែ...............ឆ្នាំ.............. លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

This certificate is issued in accordance with the provisions of the Law on Management of Pesticide & Fertilizer in force and unless sooner revoked by Ministry of Agriculture, Forestry & Fisheries, will expire on.............................................

**រដ្ឋមន្ត្រី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**

លេខ : ១៦០៧ ឧស្សាហកម្ម - រ.ចក.

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២២៤៧ /១២ គ.វ.ក ចុះថ្ងៃទី០១.១០.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ីអ៊ិនស៍ (ខេមបូឌា) ចុះថ្ងៃទី២១.០៨.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីអ៊ិនស៍ (ខេមបូឌា) (EINS (CAMBODIA) CO., LTD.) តំណាងដោយលោក KIM TAE HYUNG សញ្ជាតិកូរ៉េ អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខM52951066 ចុះថ្ងៃទី០៩.១០.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ 601-ho Yonsei Rivervill, Chungdam-dong, Kangnam-gu, Seoul, Korea, ជាម្ចាស់ រោងចក្រធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ អ៊ីអ៊ិនស៍ (ខេមបូឌា) "*
**ទីតាំងរោងចក្រ ៖** *" ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ១១០៩ រ.៥៤ - កន - ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២

# <u>ប្រកាសបង្កើតរោងចក្រ</u>

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២១៩៤ /១២ គ.វ.ក ចុះថ្ងៃទី២៥.០៩.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ៃស៊ីង ប្លាស្ទិក ប្រដាក់ (ខេមបូឌា) ចុះថ្ងៃទី១៣.០៩.២០១២

## <u>សម្រេច</u>

**<u>ប្រការ១:</u>** អនុញ្ញាតឲ្យក្រុមហ៊ុន វ៉ៃស៊ីង ប្លាស្ទិក ប្រដាក់ (ខេមបូឌា) (WAI SHING PLASTIC PRODUCTS (CAMBODIA) CO., LTD. តំណាងដោយ លោក YAU WAI SHING សញ្ជាតិចិន(ហុងកុង) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខHA9022630 ចុះថ្ងៃទី[illegible].១១.២០០៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ 12/F, chevaliar Commercial Centre, 8 Wang Hoi Street, Kowloon, HK. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ ដែលមានមុខសញ្ញាដូចខាងក្រោម ៖

| **-ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| តម្លក់ព្យួរសម្លៀកបំពាក់ពីប្លាស្ទិក | ២២២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតប្រដាប់ព្យួរសម្លៀកបំពាក់ ជ័រស៊ីង ប្លាស្ទិក ប្រដាក់ (ខេមបូឌា) "*
- **ទីតាំងរោងចក្រ ៖** *" ភូមិត្រពាំងសាំងជៀក ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤„ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ